**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

- លេខ : ២៦៥/០០៣/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៦/០០៤/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៧/០០៥/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៨/០០៦/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៩/០០៧/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៧០/០០៨/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៦២/០០២/២០១៧ កបធ.ច
ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញសេចក្ដីសម្រេចលេខ ០០៨ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០០៩ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០១៤ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោកស្រី **ឆៀង សម្បត្តិម៉ូនី** ជូនលោក **ភាត់ កុម្ភារ** ក្នុងការដាក់ពាក្យប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **សាន់ ប៊ុណ្ណាយ៉ុង** ជូនលោក **ភាត់ កុម្ភារ** ក្នុងការដាក់ពាក្យប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០០៨ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ឈឹម សុខពៅ** ជូនលោក **ភាត់ កុម្ភារ** ក្នុងការដាក់ពាក្យប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០០៩ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧
- បានឃើញលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ម៉ាង ចិន្តា** ជូនលោក **ភាត់ កុម្ភារ** ក្នុងការដាក់ពាក្យប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០១៤ លេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ និង លេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧
- បានឃើញពាក្យបណ្ដឹងចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់លោក **ភាត់ កុម្ភារ** តំណាងឲ្យលោកស្រី **ឆៀង សម្បត្តិម៉ូនី** លោក **សាន់ ប៊ុណ្ណាយ៉ុង** លោក **ឈឹម សុខពៅ** និងលោក **ម៉ាង ចិន្តា** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០០២ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ លេខ ០០៨ លេខ ០០៩ លេខ ០១៤ លេខ ០១៧ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៧ និងលេខ ០២០ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ភាត់ កុម្ភារ** កាលពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ